ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១. សរណន

# សារាចរណែនាំ
## ស្តីពី
## ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មានតួនាទីស្នូលក្នុងការងារបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាព ព្រមទាំងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ កន្លងមកការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានបំពេញតួនាទីខាងលើនេះ ទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់។ ផ្អែកលើភារកិច្ចក្នុងដំណាក់កាលថ្មី ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទាមទារនូវការពង្រឹង និងពង្រីក ទាំងបរិមាណ និងគុណភាព ដើម្បីមានថាមពលគ្រប់គ្រាន់ក្នុងការបណ្តុះបណ្តាលកំលាំងពលកម្មជំនាញ ផ្នែកបច្ចេកទេស រួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ច បង្កើតឱកាសការងារដល់យុវជន យុវនារី ទាក់ទាញអ្នកវិនិយោគទុនជាតិ និងអន្តរជាតិ ព្រមទាំងដោះស្រាយបញ្ហាប្រឈមដទៃទៀត ដូចជាការចល័តកំលាំងពលកម្ម ការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ានក្រោយឆ្នាំ២០១៥។

ផ្អែកលើស្មារតីខាងលើនេះ និងអនុវត្តតាមខ្លឹមសារក្នុងសេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៥ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ ព្រមទាំងលទ្ធផលវាយតម្លៃរបស់ក្រុមការងារចំពោះស្ថានភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រាជរដ្ឋាភិបាលកំណត់ចេញនូវទិសដៅយុទ្ធសាស្ត្រសម្រាប់ការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដូចតទៅ៖

- លើកកម្ពស់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យមានប្រសិទ្ធភាពខ្ពស់ និងមានលក្ខណៈទាក់ទាញ ដើម្បីអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងបង្កើនការទទួលស្គាល់ជាសាធារណៈ។
- លើកកម្ពស់គុណភាព និងលទ្ធផលការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សំដៅបង្កើនឱកាសការងារ ផលិតភាពការងារ និងបង្កើនប្រាក់ចំណូលគ្រួសារ។
- ពង្រឹងគោលការណ៍បណ្តុះបណ្តាលប្រកបដោយសមធម៌ ដោយយកចិត្តទុកដាក់ដល់ស្ត្រីភេទ ជនបាត់បង់ឱកាស ឬមានឱកាសតិចតួចក្នុងសង្គម យុវជនទីទ័លក្រ និងសិស្សដែលបានបោះបង់ការសិក្សា។

ដើម្បីសម្រេចទិសដៅយុទ្ធសាស្ត្រខាងលើ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវអនុវត្តនូវវិធានការទាំងឡាយដូចខាងក្រោម៖

### ១. ការបណ្តុះបណ្តាលត្រូវឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ

- គណៈកម្មាធិការជាតិបណ្តុះបណ្តាល តាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវសិក្សាស្រាវជ្រាវអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារមួយ និងប្រើប្រាស់លទ្ធផលព័ត៌មាន និងទិន្នន័យ ដែលផលិតដោយទីភ្នាក់ងារជាតិនេះ ដើម្បីជាបង្អែករឹងមាំសម្រាប់រៀបចំផែនការបណ្តុះបណ្តាល ឱ្យបានឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។

- បង្កើនបរិមាណបណ្តុះបណ្តាលពលករជំនាញ និងអ្នកបច្ចេកទេសឱ្យស្របតាមស្ថានភាពទីផ្សារការងារ ដែលនៅមានភាពទូលំទូលាយ តាមរយៈការពង្រីក ឬកសាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈថ្មីៗថែមទៀត។
- បង្កើនបរិមាណបណ្តុះបណ្តាលលើមុខជំនាញដែលមានតម្រូវការទីផ្សារការងារ និងសិក្សាស្រាវជ្រាវលើមុខជំនាញថ្មីៗថែមទៀត ។
- ត្រូវបន្តធ្វើការពង្រាយការបណ្តុះបណ្តាលរយៈពេលខ្លី ឱ្យបានច្រើនថែមទៀតដល់សហគមន៍ និងបណ្តុះបណ្តាលនៅនឹងកន្លែង សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន រោងចក្រ និងមូលដ្ឋានផលិតកម្ម ឱ្យឆ្លើយតបតាមតម្រូវការការងារ និងមុខរបរនៅទីនោះ ដើម្បីបង្កើនផលិតភាពការងារ និងប្រាក់ចំណូលគ្រួសារ។
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបញ្ចូលកម្មវិធីបណ្តុះគំនិតសហគ្រិនភាពក្នុងផែនការកម្មវិធីបណ្តុះបណ្តាល ដើម្បីផ្តល់សញ្ញាណអំពីការធ្វើជំនួញ ឬការប្រកបមុខរបរដោយខ្លួនឯង។

## ២. ការធានាគុណភាពបណ្តុះបណ្តាលសំដៅបង្កើនផលិតភាព

- គណៈកម្មាធិការជាតិបណ្តុះបណ្តាល ត្រូវរៀបចំឱ្យមានជាផ្លូវការនូវក្របខណ្ឌគុណវុឌ្ឍិជាតិ អភិវឌ្ឍស្តង់ដាជាតិសមត្ថភាព ការធ្វើតេស្តបញ្ជាក់សមត្ថភាព លក្ខណៈវិនិច្ឆ័យវាយតម្លៃទទួលស្គាល់ គុណភាព វគ្គ កម្មវិធី គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបទដ្ឋានគតិយុត្តិ ហើយត្រូវដឹកនាំដំណើរការធ្វើតេស្តបញ្ជាក់សមត្ថភាពដល់ពលករជំនាញ និងធ្វើការវាយតម្លៃទទួល ស្គាល់គុណភាពបណ្តុះបណ្តាលរបស់វគ្គ កម្មវិធី និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ និងអនុវត្តបានតាមបទដ្ឋានក្របខណ្ឌគុណវុឌ្ឍិជាតិ និងស្តង់ដាជាតិសមត្ថភាពតែមួយ គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវមកធ្វើការ ចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត អាស្រ័យតាមកម្រិតសិក្សានីមួយៗរាប់បញ្ចូលទាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានច្បាប់អនុញ្ញាតហើយដោយក្រសួង ឬស្ថាប័នផ្សេងៗ។
- ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវធានាឱ្យបាននូវខ្លឹមសារ ៤យ៉ាងគឺ **ចំណេះដឹង សមត្ថភាពជំនាញ ឥរិយាបថការងារ និងសីលធម៌វិជ្ជាជីវៈ** ព្រមទាំងមានលក្ខណៈផ្សារភ្ជាប់ទៅនឹងការអនុវត្តន៍ជាក់ស្តែងក្នុងផលិតកម្ម។
- កែលម្អនូវមធ្យោបាយបច្ចេកទេសគរុកោសល្យ បំពាក់បន្ថែមនូវមូលដ្ឋានសម្ភារៈឧបទ្ទេស រោងជាង សៀវភៅឯកសារ បណ្ណាល័យ ដើម្បីឆ្លើយតបតាមការវិវឌ្ឍន៍នៃបច្ចេកវិទ្យាថ្មីៗ។
- បំពាក់បំប៉នលើកកម្ពស់សមត្ថភាពដល់មន្ត្រីគ្រប់គ្រង និងធ្វើវិក្រឹត្យការដល់សាស្ត្រាចារ្យ គ្រូបច្ចេកទេសលើកម្រិតជំនាញ និងគរុកោសល្យ ។

## ៣.ការពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- និយោជកត្រូវផ្តល់អាទិភាពដល់ពលករជំនាញដែលមានសញ្ញាបត្រ ឬវិញ្ញាបនបត្រអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងការជ្រើសរើសឱ្យចូលបម្រើការងារក្នុងរោងចក្រ សហគ្រាសរបស់ខ្លួន ព្រមទាំងត្រូវធ្វើកិច្ចសហការជាមួយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងការទទួលឱ្យសិស្សនិស្សិតធ្វើកម្មសិក្សា និងសុក្រឹតការក៏ដូចជាការផ្លាស់ប្តូរបទពិសោធនានា ដើម្បីអាចឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ទីផ្សារការងារ។
- គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវបង្កើតឱ្យមានក្រុមការងារទទួលបន្ទុកធ្វើទំនាក់ទំនង ជាមួយសមាគមវិជ្ជាជីវៈ មូលដ្ឋានផលិតកម្ម សេវាកម្ម រោងចក្រ សហគ្រាសដើម្បីជួយរកការងារឱ្យសិស្ស-និស្សិត ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ។

- ត្រូវសិក្សាស្រាវជ្រាវ រៀបចំឱ្យមានមូលដ្ឋានគតិយុត្តិស្តីពីកាតព្វកិច្ចរួមចំណែកក្នុងការបណ្តុះបណ្តាលអ្នកបច្ចេកទេស និងវិជ្ជាជីវៈពីនិយោជក និងមូលដ្ឋានគតិយុត្តិស្តីពីការប្រើប្រាស់កំលាំងពលកម្មជំនាញ ដែលធ្លាប់បានទទួលការបណ្តុះបណ្តាល ។

### ៤. សមធម៌ក្នុងការបណ្តុះបណ្តាល

បន្តអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវគោលការណ៍សមធម៌របស់រាជរដ្ឋាភិបាល ក្នុងការបណ្តុះបណ្តាលត្រូវយកចិត្តទុកដាក់ផ្តល់អាទិភាពចំពោះស្ត្រីភេទ ជនពិការ ជនបាត់បង់ឱកាស យុវជនទីទ័លក្រ និងសិស្សដែលបានបោះបង់ការសិក្សា ដើម្បីមានជំនាញមានមុខរបរអាចរួមរស់បានសមរម្យក្នុងសង្គមដូចសមាជិកដទៃទៀត។ ដើម្បីសម្រេចគោលការណ៍នេះ ត្រូវមានវិធានការអាទិភាព រួមមាន ទាំងប្រាក់អាហារូបករណ៍ និងការបង្កើតអន្តេវាសិកដ្ឋានសម្រាប់ក្រុមមុខសញ្ញាខាងលើ។

### ៥. ការលើកកម្ពស់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍ សង្គម-សេដ្ឋកិច្ច

- រៀបចំវិធានការនានា លើកទឹកចិត្តដល់គ្រូបច្ចេកទេស និងសិស្ស-និស្សិតកំពុងសិក្សា ឬបម្រើការក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីទាក់ទាញដល់អ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេសថ្មីៗ និងសិស្សពូកែៗ ងាកមករៀន ឬបម្រើការងារក្នុងវិស័យនេះ។
- ដៃគូអភិវឌ្ឍន៍ អង្គការនានា ក្រុមហ៊ុន ឯកជន និងសប្បុរសជន គប្បីពិនិត្យលទ្ធភាពជួយអភិវឌ្ឍសាលាបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងផ្តល់អាហារូបករណ៍ ដល់យុវជន យុវនារីទីទ័លក្រ ដែលស្ម័គ្រចិត្តចូលរៀនផ្នែកបច្ចេកទេស និងវិជ្ជាជីវៈ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវគ្រប់គ្រងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធានាបាននូវគុណភាពព្រមទាំងត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តិ និងសារាចរណែនាំលម្អិត ដើម្បីអនុវត្តវិធានការទាំងឡាយខាងលើនេះ និងធ្វើការតាមដានត្រួតពិនិត្យវាយតម្លៃលទ្ធផលជូនរាជរដ្ឋាភិបាល។

ទទួលបានសារាចរណែនាំនេះ គណៈកម្មាធិការជាតិបណ្តុះបណ្តាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការខេត្តបណ្តុះបណ្តាល ព្រមទាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទាំងផ្នែករដ្ឋ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលត្រូវអនុវត្តសារាចរណែនាំនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់សាលារាជធានី-ខេត្ត*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*